**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

# សេចក្តីជូនដំណឹង

## ស្តីពី

## លទ្ធផលបណ្តោះអាសន្ននៃការដេញថ្លៃប្រេកង់វិទ្យុសម្រាប់ទូរស័ព្ទចល័តជំនាន់ទី៤ (4G) ក្រោមទម្រង់ជា Comparative Tender (ឬ Beauty Contest)

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សូមជូនដំណឹងចំពោះបុគ្គលទាំងឡាយដែលបានដាក់ឯកសារចូលរួមដេញថ្លៃដើម្បីទទួលបានសិទ្ធិប្រើប្រាស់ប្រេកង់វិទ្យុសម្រាប់ទូរស័ព្ទចល័តលើទីតាំងបន្ទារប្រេកង់វិទ្យុ 829.5-834.5/ 874.5-879.5 MHz និង 2 510-2 520/2 630-2 640 MHz សម្រាប់បច្ចេកវិទ្យាទូរស័ព្ទចល័តជំនាន់ទី៤ (4G) ក្រោមទម្រង់ជា Comparative Tender (ឬ Beauty Contest) ឱ្យបានជ្រាបថា យោងតាមការសម្រេចរបស់កិច្ចប្រជុំក្រុមការងារដេញថ្លៃ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការពិនិត្យ វាយតម្លៃ និងសម្រេចលើពាក្យសុំនិងឯកសារដេញថ្លៃប្រេកង់វិទ្យុសម្រាប់ទូរស័ព្ទចល័តជំនាន់ទី៤ (4G) ក្រោមទម្រង់ជា Comparative Tender (ឬ Beauty Contest) បុគ្គលដែលទទួលបានជ័យជំនះដែលនឹងទទួលបានសិទ្ធិប្រើប្រាស់ប្រេកង់វិទ្យុសម្រាប់ទូរស័ព្ទចល័តលើទីតាំងបន្ទារប្រេកង់វិទ្យុ 2 510-2 520/2 630-2 640 MHz គឺ **ក្រុមហ៊ុន សៅ អ៊ីស្ត អេស៊ា ធេលេខម (ខេមបូឌា) -** SOUTH EAST ASIA TELECOM (CAMBODIA) CO.,LTD (SEATEL) ។

ដោយឡែក យោងតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល ប្រេកង់វិទ្យុសម្រាប់ទូរស័ព្ទចល័តលើទីតាំងបន្ទារប្រេកង់វិទ្យុ 829.5-834.5/874.5-879.5 MHz ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍សូមធ្វើការផ្អាកដំណើរការដេញថ្លៃ ក្រោមទម្រង់ជា Comparative Tender (ឬ Beauty Contest) ជាបណ្តោះអាសន្ន ។

សេចក្តីដូចបានជម្រាបជូនខាងលើ បុគ្គលដែលបានដាក់ឯកសារដេញថ្លៃ អាចតវ៉ាចំពោះសេចក្តីសម្រេចរបស់ក្រុមការងារដេញថ្លៃក្នុងរយៈពេល ០៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃប្រកាសលទ្ធផលបណ្តោះអាសន្ននេះ។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦